# សន្តិកម្ម I
# - សន្តិកម្មតាមច្បាប់ -

SHINODA Yoichiro
Attorney at Law (Japan)

# មាតិកា ( សន្តតិកម្មតាមច្បាប់ )

1 សញ្ញាណទូទៅស្ដីពីសន្តតិកម្ម ( សន្តតិកម្មតាមច្បាប់ និង សន្តតិកម្មតាមមតកសាសន៍ )

2 បញ្ហាជុំវិញសន្តតិជន

3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

4 បញ្ហាជុំវិញការបែងចែកមត៌ក

# 1សញ្ញាណទូទៅស្ដីពីសន្តតិកម្ម
# (1) ករណីសន្តតិកម្មតាមច្បាប់

ការចាប់ផ្ដើមសន្តតិកម្ម=
មរណភាពរបស់មតកជន
(CC1145 I )

ការកំណត់សន្តតិជន=
តើនរណាត្រូវទទួលសន្តតិកម្ម？
(CC ចាប់ពី 1156)

ការកំណត់ចំណែកមត៌ក=
តើការទទួលសន្តតិកម្មធ្វើឡើងដោយរបៀបណា？
(CC ចាប់ពី1156)

ការពិភាក្សាបែងចែកមត៌ក ឬ
<u>ការបែងចែកដោយតុលាការ</u>=
តើបែងចែកដោយរបៀបណា？
(CC ចាប់ពី 1266)

រឿងក្ដីរដ្ឋប្បវេណី
ដែលមិនមែនជា
បណ្ដឹង

※ ក្នុងករណីដែលមានវិវាទអំពីសន្តតិជន ឬ ចំណែកមត៌ក ភាគីអាចកំណត់បញ្ហាទាំងនេះ ដោយប្រើ បណ្ដឹងរដ្ឋប្បវេណី ឬ បណ្ដឹងទាក់ទងនឹងឋានៈបុគ្គល។ e.g. <u>បណ្ដឹងទាមទារឲ្យបញ្ជាក់មត៌ក</u> <u>បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិសន្តតិកម្ម</u> <u>បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃសុំកូន</u> ជាដើម

# 1សញ្ញាណទូទៅស្តីពីសន្តតិកម្ម

## (2) ករណីសន្តតិកម្មតាមមតកសាសន៍

សន្តតិកម្មដែលបានធ្វើឡើង
តាមរយៈមតកសាសន៍
(ការពិភាក្សាបែងចែកមត៌ក ឬ ការ
បែងចែកមត៌កដោយតុលាការ)

ការចាប់ផ្តើមសន្តតិកម្ម=មរណភាព
របស់មតកជន (CC1145 I )



លិខិត
មតកសាសន៍

រឿងក្តី
រដ្ឋប្បវេណីដែល
មិនមែនជា
បណ្តឹង

<u>ការពិនិត្យបញ្ជាក់អំពី</u>
<u>លិខិតមតកសាសន៍</u>
(CC1213)

រឿងក្តី
រដ្ឋប្បវេណី

ភាគបម្រុង
→ <u>រឿងក្តីដែល</u>
<u>ទាមទារឲ្យកាត់បន្ថយ</u>
<u>ដើម្បីបង្គ្រប់ភាគបម្រុង</u>

※ អាចមានវិវាទអំពីមោឃភាពនៃមតកសាសន៍
→ <u>បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃមតកសាសន៍</u> (រឿងក្តីរដ្ឋប្បវេណី)

# 2 បញ្ហាជុំវិញសន្តតិជន

## (1) វិធានជាមូលដ្ឋានដែលទាក់ទងនឹងការកំណត់អំពីសន្តតិជន

A. សហព័ទ្ធ (សន្តតិជនជាសហព័ទ្ធ) : ក្នុងករណីដែលមតកជនមានសហព័ទ្ធ សហព័ទ្ធនោះនឹងត្រូវក្លាយជាសន្តតិជនជានិច្ច (CC1161Ⅰ)

B. សន្តតិជនជាញាតិលោហិតដែលកំណត់តាមលំដាប់

① លំដាប់ទី 1 : កូនរបស់មតកជន (CC1156)

※ អាចមានសន្តតិកម្មជំនួស ឬ សន្តតិកម្មជំនួសជាបន្តបន្ទាប់ (CC1157)

② លំដាប់ទី 2 : បុព្វញាតិផ្ទាល់ (CC1159)

③ លំដាប់ទី 3 : បងប្អូនបង្កើត (CC1160)

※ អាចមានសន្តតិកម្មជំនួស (CC1160Ⅲ、CC1157Ⅰ)

## 2 បញ្ហាជុំវិញសន្តតិជន

### (2) វិធានជាមូលដ្ឋានដែលទាក់ទងនឹងការកំណត់អំពីសន្តតិជន



# 2 បញ្ហាជុំវិញសន្តតិជន
# (3) ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

A. ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

រឿងក្តីវដ្ដប្បវេណីដែលមិនមែនជាបណ្តឹង

| | |
|---|---|
| ការយល់ព្រមទាំងស្រុង (CC1254) | • សន្តតិជនដែលបានយល់ព្រមទាំងស្រុង ត្រូវទទួលបន្តដោយគ្មានកម្រិតនូវសិទ្ធិ និងកាតព្វកិច្ចរបស់មតកជន (CC1254) |
| ការយល់ព្រមដោយមានកម្រិត (CC1256) | • សន្តតិជនដែលបានយល់ព្រមដោយមានកម្រិត ត្រូវទទួលខុសត្រូវលើកាតព្វកិច្ច ប៉ុន្តែត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនទទួលបានតាមរយៈសន្តតិកម្ម (CC1256 I ) |
| ការបោះបង់សន្តតិកម្ម (CC1260) | • សន្តតិជនដែលបានបោះបង់សន្តតិកម្ម ត្រូវបានចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូង (CC1261) |

រឿងក្តីវដ្ដប្បវេណីដែលមិនមែនជាបណ្តឹង

# 2 បញ្ញាជុំវិញសន្តតិជន

## (3) ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

B. ការលុបចោលការយល់ព្រម ឬ ការបោះបង់ （CC1252)

ការយល់ព្រម ឬ ការបោះបង់អាចលុបចោលបាន ដោយមូលហេតុ<u>ការបង្ហាញឆន្ទៈមានវិការៈ</u> （CC1252Ⅱ） ។

ការភាន់ច្រឡំ ការឆបោក និង ការគម្រាមគំហែង ជាអាទិ៍ (CC345)

↓

បុគ្គលដែលអាចលុបចោលការយល់ព្រមដោយកម្រិត ឬ ការបោះបង់ត្រូវដាក់ពាក្យសុំទៅតុលាការ （CC1252Ⅲ） ។

រឿងក្តី
រដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង

# 2 បញ្ហាជុំវិញសន្តតិជន

## (3) ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

B. ការលុបចោលការយល់ព្រម ឬ ការបោះបង់ (CC1252)



# 2 បញ្ហាជុំវិញសន្តតិជន

## (3) ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

C. បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃការបោះបង់សន្តតិកម្ម



## 2 បញ្ហាជុំវិញសន្តតិជន

## (3) ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

C. បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃការបោះបង់សន្តតិកម្ម



# 2 បញ្ហាជុំវិញសន្តតិជន

## (3) ការយល់ព្រម និង ការបោះបង់សន្តតិកម្ម

រឿងក្តីរដ្ឋប្បវេណី

### C. បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃការបោះបង់សន្តតិកម្ម



ម្ចាស់បំណុលX

បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមោឃភាពនៃ
ការបោះបង់សន្តតិកម្ម (Y1 Y2បាន
ចាត់ចែងមត៌កមួយផ្នែក)



“ឧទាហរណ៍
នៃសេចក្តីសម្រេចបញ្ចប់”
បញ្ជាក់ថា ការបោះបង់
សន្តតិកម្មរបស់មតកជន W
(អាសយដ្ឋាន )ដោយចុង
ចម្លើយY1 និង Y2 ដែល
បានធ្វើនៅថ្ងៃទី○ ខែ○ ឆ្នាំ
○○ គឺមោឃភាព



ម្ចាស់បំណុលX

រឿងក្តីទាមទារឲ្យសងប្រាក់កម្ចី
Y1 : 5,000 $
Y2 : 5,000 $



## 2 បញ្ហាជុំវិញសន្តតិជន

## (4) អភ័ព្វបុគ្គល និង ការផ្ដាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន

A. អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍ (CC1150)




មូលហេតុដែលពុំអាចក្លាយជាសន្តតិជន

→ D មិនអាចក្លាយជាសន្តតិជនជាស្វ័យប្រវត្តិ

(មិនចាំបាច់នីតិវិធីពិសេសទេ)

## 2 បញ្ហាជុំវិញសន្តតិជន
## (4) អភ័ព្វបុគ្គល និង ការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន

A. អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍ (CC1150)

ក. បុគ្គលដែលបានទទួលទោស ដោយមានចេតនាធ្វើឃាត ឬ ប៉ុនប៉ងធ្វើឃាតលើមតកជន ឬ លើជនដែលមានលំដាប់សន្តតិកម្មមុន ឬ លំដាប់ស្មើគ្នា ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី។

ខ. បុគ្គលដែលដឹងអំពីការសម្លាប់មតកជន តែមិនបានរាយការណ៍ ឬ មិនបានប្តឹង។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលបុគ្គលនោះ មិនអាចវិនិច្ឆ័យអំពើល្អ ឬ អាក្រក់បាន ឬ ករណីដែលអ្នកសម្លាប់ជាសហព័ទ្ធ ឬ ញាតិលោហិតខ្សែផ្ទាល់របស់បុគ្គលនោះ។

គ. បុគ្គលដែលបានរារាំងមតកជនក្នុងការធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង។

ឃ. បុគ្គលដែលបានឲ្យមតកជនធ្វើ លុបចោល ឬ កែប្រែមតកសាសន៍ស្តីពីសន្តតិកម្ម ដោយការឆបោក ឬ គម្រាមកំហែង។

ង. បុគ្គលដែលបានក្លែង កែបន្លំ បំផ្លាញចោល ឬ លាក់ទុកនូវលិខិតមតកសាសន៍ស្តីពីសន្តតិកម្មរបស់មតកជន។

# 2 បញ្ហាជុំវិញសន្តតិជន

## (4) អភ័ព្វបុគ្គល និង ការផ្ដាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន

A.  អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍  (CC1150)

“ឧទាហរណ៍នៃការបញ្ជាក់អំពីនត្តិភាពនៃសិទ្ធិសន្តតិកម្ម”






C

ខ្ញុំបានឃើញ D កាន់លិខិតមតកសាសន៍ដែល A បានសរសេរ។ D ប្រាកដជាលាក់លិខិតមតកសាសន៍នោះ ឬបោះចោលបាត់ហើយ !



D

ខ្ញុំមិនដែលបានឃើញលិខិតមតកសាសន៍របស់ A អីទេ។ ខ្ញុំមិនបានលាក់ ឬ បោះចោលលិខិតមតកសាសន៍ទេ។

# 2 បញ្ហាជុំវិញសន្តតិជន

## (4) អភ័ព្វបុគ្គល និង ការផ្ដាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន

A. អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍ (CC1150)

“បណ្ដឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិសន្តតិកម្ម”

រឿងក្ដីរដ្ឋប្បវេណី




※ តម្រូវឲ្យសហសន្តតិជនទាំងអស់ធ្វើជាភាគី (សហបណ្ដឹងជាចាំបាច់ដោយពិត (CCP41) )

# 2 បញ្ហាជុំវិញសន្តតិជន

## (4) អភ័ព្វបុគ្គល និង ការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន

A. អភ័ព្វបុគ្គលនៃសន្តតិកម្ម ជាអាទិ៍ (CC1150)

“ឧទាហរណ៍នៃសេចក្តីសម្រេចបញ្ជាប់អំពីបណ្តឹងទាមទារឲ្យបញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិសន្តតិកម្ម”



C

បណ្តឹងទាមទារឲ្យបញ្ជាក់
អំពីនត្ថិភាពនៃសិទ្ធិសន្តតិកម្ម



បញ្ជាក់ថា ចុងចម្លើយD
មិនមានឋានៈជា
សន្តតិជនចំពោះមត៌ក
របស់មតកជនAទេ។

# 2 បញ្ហាជុំវិញសន្តតិជន

## (4) អស័ព្ទបុគ្គល និង ការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន

### B. ការផ្តាច់មត៌កពីសន្តតិជន (CC1151)




① ពាក្យសុំផ្តាច់មត៌ក (CC1151)

or

② ការបង្ហាញឆន្ទៈអំពីការផ្តាច់មត៌កតាមរយៈមតកសាសន៍ (CC1152)

→ Dនឹងលែងក្លាយជាសន្តតិជន តាមរយៈដីកាសម្រេចរបស់តុលាការ

※ ក៏អាចលុបចោលនូវការផ្តាច់មត៌កដែលធ្វើឡើងដោយមតកជនផងដែរ (CC1154)

## 2 បញ្ហាជុំវិញសន្តតិជន

### (4) អភ័ព្វបុគ្គល និង ការផ្ដាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន

B. ការផ្ដាច់មត៌កពីសន្តតិជន (CC1151)

ក.បើបានធ្វើបាបចំពោះមតកជន។
ខ.បើបានប្រមាថមតកជនយ៉ាងធ្ងន់ធ្ងរ។
គ.បើអាចមកមើលថែទាំមតកជននៅពេលដែលមានជម្ងឺ ប៉ុន្តែមិនមកថែទាំ។
ឃ.បើត្រូវទទួលបានសាលក្រម ឬ សាលដីកាផ្តន្ទាទោសឲ្យជាប់ពន្ធនាគារមួយជីវិត។
ង.បើបានប្រព្រឹត្តអំពើល្មើសធ្ងន់ធ្ងរគួរឲ្យកត់សំគាល់ជាអាទិ៍។

## 2 បញ្ហាជុំវិញសន្តតិជន

### (4) អភ័ព្វបុគ្គល និង ការផ្តាច់មត៌កពីជនដែលត្រូវបានសន្មតថាជាសន្តតិជន

B. ការផ្តាច់មត៌កពីសន្តតិជន (CC1151)

"ឧទាហរណ៍នៃសេចក្តីសម្រេចបញ្ចប់នៃរឿងក្តីដែលបានដាក់ពាក្យសុំផ្តាច់មត៌ក"

"ផ្តាច់ភាគីម្ខាងទៀត ឈ្មោះ D ពីសន្តតិកម្មរបស់អ្នកដាក់ពាក្យសុំ A។"

## 2 បញ្ហាជុំវិញសន្តតិជន

## (5) ករណីនត្ថិភាពនៃសន្តតិជន

"ប្រសិនបើពុំច្បាស់ថាមានសន្តតិជនទេ" (CC1290) គឺជាអ្វី?

1. ក្នុងករណីដែលមតកជនពុំមានទាំងសហព័ទ្ធ កូន ឪពុកម្តាយ បងប្អូនបង្កើត និង សន្តតិជនជំនួសរបស់អ្នកទាំងនេះ។
2. ទោះបីជាមានអ្នកដែលត្រូវបានសន្មតថាជាសន្តតិជនក៏ដោយ ប៉ុន្តែ អ្នកនោះត្រូវជាអភ័ព្វបុគ្គល ឬ ត្រូវបានផ្តាច់មត៌ក ហើយមិនមានសន្តតិជនជំនួសឲ្យអ្នកដែលត្រូវបានសន្មតថាជាសន្តតិជននោះ។
3. ករណីដែលមិនមានទាំងអច្ច័យលាភីសកល បន្ថែមពីលើចំណុចទី 1 និងទី 2។
4. ករណីដែលពុំដឹងច្បាស់អំពីទំនាក់ទំនងញាតិរបស់មតកជន។

# 2 បញ្ហាជុំវិញសន្តតិជន

## (5) ករណីនត្ថិភាពនៃសន្តតិជន

### A. ការជ្រើសតាំងអ្នកគ្រប់គ្រងមត៌ក និង នីតិវិធីជម្រះបញ្ជី

ការជ្រើសតាំងអ្នកគ្រប់គ្រង និង
ការជូនដំណឹងជាសាធារណៈ

(CC1291)

រឿងក្តី
រដ្ឋប្បវេណីដែល
មិនមែនជាបណ្តឹង

ការស្វែងរកសន្តតិជន (CC1297)
និង ការជម្រះបញ្ជី (CC1292IV・
1283、1298)

ការជូនដំណឹងជាសាធារណៈ និង
ការដាស់តឿនចំពោះម្ចាស់បំណុលជា
អាទិ៍ (CC1296 I) និង ការសង
(CC1296 II・ចាប់ពី CC1283)

# 2 បញ្ហាជុំវិញសន្តតិជន
## (5) ករណីនត្ថិភាពនៃសន្តតិជន

B.ការបង្វែរទ្រព្យសម្បត្តិដែលនៅសល់

(A) ការបែកមត៌កឲ្យទៅជនដែលមាននិស្ស័យពិសេស (CC1299)

រឿងក្តី
រដ្ឋប្បវេណីដែល
មិនមែនជាបណ្តឹង

- លក្ខខណ្ឌ : ① មានមត៌កដែលនៅសេសសល់ក្រោយការជម្រះបញ្ជី
  ② មានពាក្យសុំរបស់ជនដែលមាននិស្ស័យពិសេស
  ③ "បើយល់ឃើញថាសមរម្យ" (CC1299 I )
- សុពលភាព : តុលាការអាចបែកមួយផ្នែកនៃមត៌កដែលនៅសេសសល់ក្រោយការជម្រះបញ្ជី ទៅឲ្យជនដែលមាននិស្ស័យពិសេស។

(B) ការបង្វែរឲ្យរតនាគារជាតិ (CC1300)

មត៌កដែលនៅសេសសល់ចុងក្រោយ ត្រូវធ្លាក់ទៅរតនាគារជាតិ។

## 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

### (1) ចំណែកមត៌កដែលច្បាប់បានកំណត់

A. ទំនាក់ទំនងរវាងសហព័ទ្ធ និង សន្តតិជនជាញាតិលោហិត

ករណីសិក្សា 1 : សហព័ទ្ធ និង បច្ឆាញាតិផ្ទាល់ (CC1162①)




ចំណែកមត៌កដែលច្បាប់បានកំណត់របស់សន្តតិជនម្នាក់ៗគឺ ស្មើគ្នា

→ B 1/3

C 1/3

D 1/3

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (1) ចំណែកមត៌កដែលច្បាប់បានកំណត់

A. ទំនាក់ទំនងរវាងសហព័ទ្ធ និង សន្តតិជនជាញាតិលោហិត

ករណីសិក្សា 2 : សហព័ទ្ធ និង បុព្វញាតិផ្ទាល់（CC1162②）




ចំណែកមត៌ករបស់សហព័ទ្ធ : ចំណែកមត៌ករបស់បុព្វញាតិផ្ទាល់

＝1 : 2

→ B 1/3

E 1/3

F 1/3

## 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

### (1) ចំណែកមត៌កដែលច្បាប់បានកំណត់

A. ទំនាក់ទំនងរវាងសហព័ទ្ធ និង សន្តតិជនជាញាតិលោហិត

ករណីសិក្សា 3 : សហព័ទ្ធ និង បុព្វញាតិផ្ទាល់ម្នាក់ (CC1162② វាក្យ.ទី2)




ចំណែកមត៌ករបស់សហព័ទ្ធ : ចំណែកមត៌ករបស់បុព្វញាតិផ្ទាល់

＝1 : 1

→ B 1/2

F 1/2

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (1) ចំណែកមត៌កដែលច្បាប់បានកំណត់

A. ទំនាក់ទំនងរវាងសហព័ទ្ធ និង សន្តតិជនជាញាតិលោហិត

ករណីសិក្សា 4 ： សហព័ទ្ធ និង បុព្វញាតិក្រៅពីឪពុក ម្តាយ （CC1162③）




ចំណែកមត៌ករបស់សហព័ទ្ធ ： ចំណែកមត៌ករបស់បុព្វញាតិក្រៅពីឪពុក ម្តាយ

＝1 ： 1

→ B 1/2

G 1/2

## 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

### (1) ចំណែកមត៌កដែលច្បាប់បានកំណត់

A. ទំនាក់ទំនងរវាងសហព័ទ្ធ និង សន្តតិជនជាញាតិលោហិត

ករណីសិក្សា 5 : សហព័ទ្ធ និង បងប្អូនបង្កើតរបស់មតកជន (CC1162③)




ចំណែកមត៌ករបស់សហព័ទ្ធ : ចំណែកមត៌ករបស់បងប្អូនបង្កើត＝1 : 1

→ B 1/2

H 1/4

I 1/4

## 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

### (1) ចំណែកមត៌កដែលច្បាប់បានកំណត់

B. ចំណែករវាងសន្តតិជនជាញាតិលោហិតដែលស្ថិតក្នុងលំដាប់ដូចគ្នា

- គោលការណ៍ស្តីអំពីសន្តតិកម្មដោយចំណែកស្មើគ្នា （CC1156Ⅱ、1159Ⅱ、1160Ⅱវាក្យ.ទី1)

  → សន្តតិជនជាញាតិលោហិតទាំងឡាយដែលស្ថិតក្នុងលំដាប់ដូចគ្នា មានចំណែកមត៌កស្មើៗគ្នា។

- ករណីលើកលែងចំពោះបងប្អូនបង្កើតរបស់មតកជន （CC1160Ⅱវាក្យ.ទី2)

  → ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុក ឬ ម្តាយតែម្ខាងដូចគ្នា ត្រូវមាន 1ភាគ 2 នៃចំណែកមត៌ករបស់បងប្អូនដែលមានឪពុក និង ម្តាយទាំងសងខាងដូចគ្នា។

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## ( 1 ) ចំណែកមត៌កដែលច្បាប់បានកំណត់

B. ចំណែករវាងសន្តតិជនជាញាតិលោហិតដែលស្ថិតក្នុងលំដាប់ដូចគ្នា




ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកម្ដាយទាំងសងខាងដូចគ្នា ：ចំណែកមត៌ករបស់បងប្អូនបង្កើតដែលមានឪពុកម្ដាយតែម្ខាងដូចគ្នា

＝2 ： 1

→ H 2/3

J 1/3

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (2) ចំណែកមត៌កដែលបានកំណត់

មតកជនអាចកំណត់ចំណែកមត៌ករបស់សន្តតិជនតាមមតកសាសន៍ (CC1182 I )



# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្ដែង

### A. វិធានជាមូលដ្ឋានទាក់ទងនឹងការកំណត់ចំណែកមត៌កជាក់ស្ដែង

ចំណែកមត៌កតាមច្បាប់កំណត់ ▪ ចំណែកមត៌កដែលបានកំណត់



ការទទួលផលប្រយោជន៍ពិសេស (CC1163)

ភាគនៃវិភាគទាន (CC1166)

ចំណែកមត៌កជាក់ស្ដែង

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស (CC1163)

"នៅក្នុងចំណោមសហសន្តតិជនទាំងអស់ បើមានបុគ្គលណាដែលបានទទួលប្រទានកម្ម នៅក្នុងឪកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ ដែលបានទទួលអច្ច័យទានពីមតកជននោះ តម្លៃសរុបនៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ដោយបូកបញ្ចូលនូវតម្លៃនៃប្រទានកម្មត្រូវបានចាត់ទុកជាមត៌ក ហើយចំនួនទឹកប្រាក់ដែលនៅសល់ ក្រោយពីដកតម្លៃនៃប្រទានកម្ម ឬ អច្ច័យទាននោះ ចេញពីចំណែកមត៌កដែលត្រូវបានគណនាតាមបញ្ញត្តិនៃផ្នែកទី១(សន្តតិជន) និង ផ្នែកទី២ (សន្តតិកម្មរបស់សហព័ទ្ធ) គឺជាចំណែកមត៌ករបស់បុគ្គលនោះ" (CC1163 I ) ។

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B.ការទទួលផលប្រយោជន៍ពិសេស (CC1163)

① កំណត់អំពីការទទួលផលប្រយោជន៍ពិសេស (អច្ច័យទាន ឬ ប្រទានកម្មកាលនៅរស់ដែលបានកំណត់)

② កំណត់អំពីទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌ក (ទ្រព្យសម្បត្តិដែលត្រូវមាន) ដោយការយកទ្រព្យសម្បត្តិដែលមាននៅពេលចាប់ផ្តើមសន្តតិកម្មបូកនឹងការទទួលផលប្រយោជន៍ពិសេស (ប្រទានកម្មកាលនៅរស់) ក្រៅពីអច្ច័យទាន (ការយកនូវការទទួលផលប្រយោជន៍ពិសេសត្រឡប់មកវិញ)

③ យកទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌កមកធ្វើការគណនាចំណែកមត៌ក ហើយដកនូវការទទួលផលប្រយោជន៍ពិសេស រួចគណនាចំណែកមត៌កជាក់ស្តែង

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស (CC1163)

① ការកំណត់អំពីការទទួលផលប្រយោជន៍ពិសេស (អច្ច័យទាន ឬ ប្រទានកម្មកាលនៅរស់ដែលបានកំណត់)

- អច្ច័យទាន ៖ ជាការទទួលផលប្រយោជន៍ពិសេស
- ប្រទានកម្មកាលនៅរស់ ៖ ប្រទានកម្មដែលត្រូវបានធ្វើឡើង "នៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត" ឬ "ដើម្បីមូលធននៃជីវភាពរស់នៅ" ក្រោមរូបភាពជាការទទួលផលប្រយោជន៍ពិសេស

→ សមភាពជាសត្យានុម័តរវាងសហសន្តតិជន

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស (CC1163)

① ការកំណត់អំពីការទទួលផលប្រយោជន៍ពិសេស (អច្ច័យទាន ឬ ប្រទានកម្មកាលនៅរស់ដែលបានកំណត់)

- អច្ច័យទាន៖ ជាការទទួលផលប្រយោជន៍ពិសេស
- ប្រទានកម្មនាពេលនៅរស់៖ " ប្រទានកម្មដែលត្រូវធ្វើនៅក្នុងឱកាសអាពាហ៍ពិពាហ៍ ឬ ហេតុការណ៍ផ្សេងទៀត" ឬ "ដើម្បីមូលធននៃជីវភាពរស់នៅក្រោមរូបភាពជាការទទួលផលប្រយោជន៍ពិសេស

គោលគំនិតនៃប្រព័ន្ធស្តីពីការទទួលផលប្រយោជន៍ពិសេស = សមភាពជាសត្យានុម័តរវាងសហសន្តតិជន
→ ធ្វើការពិចារណាដោយផ្តោតលើតុល្យភាពជាមួយនឹងសន្តតិជនផ្សេងទៀត

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស (CC1163)

②ការយកការទទួលផលប្រយោជន៍ពិសេសត្រឡប់មកវិញ → ទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌ក

- "តម្លៃនៃមត៌កដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម" = បញ្ជាក់ឲ្យបានច្បាស់លាស់អំពីទ្រព្យសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម

※ ត្រង់ចំណុចនេះ មិនគិតអំពីកាតព្វកិច្ចរបស់មតកជនទេ

ទ្រព្យសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម + ការទទួលយកផលប្រយោជន៍ពិសេសដែលបានដកអច្ច័យទានចេញ =ទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌ក

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលយកផលប្រយោជន៍ពិសេស (CC1163)

"ករណីសិក្សា1"

នៅពេលទទួលមរណភាព ឪពុកដែលត្រូវជាមតកជនមានដី និង អាគារដែលមានតម្លៃប្រហែល 400,000$ និង ប្រាក់បញ្ញើចំនួន 100,000$។ ហើយគាត់មានកាតព្វកិច្ចចំនួន 100,000$ ចំពោះធនាគារដែលជាម្ចាស់បំណុល។ សន្តតិជនមានដូចជា A、B និង C ដែលត្រូវជាកូនរបស់មតកជន។ នៅពេលដែលកូនប្រុសច្បង A បានចាប់ផ្តើមអាជីវកម្មរបស់ខ្លួនដោយខ្លួនឯង ឪពុកបានប្រគល់ប្រាក់ចំនួន 100,000$ ឲ្យទៅ A។

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស (CC1163)

<ករណីសិក្សា 1 >



# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស（CC1163）

"ករណីសិក្សា 1"

① "តម្លៃនៃទ្រព្យសម្បត្តិដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម" = 500,000 $
( ដី និង អាគារ 400,000 $ + ប្រាក់បញ្ញើ 100,000$ )

② ការទទួលផលប្រយោជន៍ពិសេសរបស់ A = 100,000 $

③ ទ្រព្យដែលត្រូវបានចាត់ទុកថាជាមត៌ក = 600,000$ ( ទ្រព្យសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម 500,000$ + ការទទួលផលប្រយោជន៍ពិសេសរបស់ A 100,000$ )

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស (CC1163)

"ករណីសិក្សា 1"

④ ការគណនាចំណែកមត៌កជាក់ស្តែង

A : 100,000$ (600,000$/3នាក់ - ការទទួលផលប្រយោជន៍ពិសេស 100,000$)

B : 200,000$ (600,000$/3នាក់)

C : 200,000$ (600,000$/3នាក់)

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស（CC1163）

"ករណីសិក្សា 2"

នៅពេលទទួលមរណភាពឪពុកដែលត្រូវជាមតកជន មានដី និង អាគារដែលមានតម្លៃស្មើនឹង 400,000$ និង ប្រាក់បញ្ញើចំនួន 100,000$ ។ ហើយគាត់មានកាតព្វកិច្ចចំនួន 100,000$ ចំពោះធនាគារដែលជាម្ចាស់បំណុល។ សន្តតិជនមានដូចជា A、B、និង C ដែលជាកូនរបស់មតកជន។ នៅពេលកូនប្រុសច្បង A បានចាប់ផ្តើមអាជីវកម្មរបស់ខ្លួនដោយខ្លួនឯង ឪពុកបានផ្តល់ប្រាក់ឲ្យ A ចំនួន 400,000$ ។

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស（CC1163）

“ករណីសិក្សា 2 ”



# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាមូលដ្ឋាន

B. ការទទួលផលប្រយោជន៍ពិសេស（CC1163）
"ករណីសិក្សា 2"

① "តម្លៃទ្រព្យសម្បត្តិដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម" ＝ 500,000$(ដី និង អាគារ 400,000$ + ប្រាក់បញ្ញើ 100,000 $)

② ការទទួលផលប្រយោជន៍ពិសេសរបស់ A = 400,000 $

③ ទ្រព្យដែលត្រូវចាត់ទុកថាជាមត៌ក ＝ 900,000$ (ទ្រព្យសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម 500,000$ + ការទទួលផលប្រយោជន៍ពិសេសរបស់ A 400,000$)

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

B. ការទទួលផលប្រយោជន៍ពិសេស（CC1163）

＜ករណីសិក្សា 2 ＞

④ ការគណនាចំណែកមត៌កជាក់ស្តែង

CC1165 Ⅰ

A： -100,000$（900,000$/3នាក់—ការទទួលផលប្រយោជន៍ពិសេស 400,000$）→ 0$

B：300,000$（900,000$/3នាក់）→ 250,000$

C：300,000$（900,000$/3នាក់）→ 250,000$

CC1165 Ⅱ

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

C. ភាគនៃវិភាគទាន (CC1166)

"ក្នុងចំណោមសហសន្តតិជនទាំងឡាយ បើមានបុគ្គលណាបានធ្វើវិភាគទានពិសេស ដើម្បីថែរក្សា ឬ បង្កើនទ្រព្យសម្បត្តិរបស់មតកជន ដោយការផ្តល់សេវកម្មលើកិច្ចការរបស់មតកជន ឬ ដោយការផ្តល់តាវកាលិកលើទ្រព្យសម្បត្តិ ឬ ដោយការថែទាំព្យាបាលមតកជន ឬ ដោយវិធីផ្សេងទៀត តម្លៃដែលដកភាគនៃវិភាគទានរបស់បុគ្គលនោះដែលបានកំណត់តាមការពិភាក្សារបស់សហសន្តតិជន ចេញពីតម្លៃមត៌កដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម ត្រូវចាត់ទុកជាមត៌ក ហើយចំនួនទឹកប្រាក់នៃភាគក្នុងសន្តតិកម្ម ដែលបានគណនាតាមបញ្ញត្តិនៃផ្នែកទី១(សន្តតិជន) និង ផ្នែកទី២ (សន្តតិកម្មរបស់សហព័ទ្ធ) បូកនឹងវិភាគទាន ត្រូវជាចំណែកមត៌ករបស់ជននោះ។ (CC1166 I )

## 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

### (3) ចំណែកមត៌កជាក់ស្តែង

c. ភាគនៃវិភាគទាន (CC1166)

① កំណត់ភាគនៃវិភាគទាន

② កំណត់អំពីទ្រព្យដែលត្រូវចាត់ទុកថាជាមត៌ក (ទ្រព្យដែលត្រូវមាន) ដោយការដកភាគនៃវិភាគទានចេញពីទ្រព្យសម្បត្តិនៅពេលចាប់ផ្តើមសន្តតិកម្ម

③ យកទ្រព្យដែលត្រូវចាត់ទុកថាជាមត៌កមក គណនាចំណែកមត៌ក រួចបូកបន្ថែមនូវភាគនៃវិភាគទាន ហើយគណនាចំណែកមត៌កជាក់ស្តែង

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

c. ភាគនៃវិភាគទាន (CC1166)

① ការកំណត់ភាគនៃវិភាគទាន

រឿងក្តីវេជ្ជបុរេណី
※ ក៏អាចមានការសម្រេចសេចក្តីនៅក្នុងនីតិវិធីបែងចែកមត៌កដែរ (ការបែងចែកដោយផ្អែកតាមតុលាការ)

"វិភាគទានពិសេស" ដែលត្រូវបានធ្វើឡើងទាក់ទងនឹង "ការរក្សាទុក ឬ ការបង្កើនទ្រព្យសម្បត្តិរបស់មតកជន"

គោលបំណងនៃប្រព័ន្ធភាគនៃវិភាគទាន = សមភាពជាសត្យានុម័តរវាងសហសន្តតិជន
→ ធ្វើការពិចារណាដោយផ្តោតលើតុល្យភាពជាមួយនឹងសន្តតិជនផ្សេងទៀត

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

c. ភាគនៃវិភាគទាន (CC1166)

② ដកភាគនៃវិភាគទាន→ទ្រព្យសម្បត្តិដែលត្រូវចាត់ទុកថាជាមត៌ក

- "តម្លៃមត៌កដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម"= ធ្វើឲ្យទ្រព្យសកម្មនៅពេលចាប់ផ្តើមសន្តតិកម្មមានភាពច្បាស់លាស់

※ ត្រង់ចំណុចនេះ មិនពិចារណាអំពីកាតព្វកិច្ចរបស់មតកជនទេ

ទ្រព្យសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម – ភាគនៃវិភាគទាន＝ទ្រព្យសម្បត្តិដែលត្រូវចាត់ទុកថាជាមត៌ក

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្ដែង

C. ភាគនៃវិភាគទាន（CC1166）
"ករណីសិក្សា1"

នៅពេលទទួលមរណភាព ឪពុកដែលត្រូវជាមតកជន មានដី និង អាគារដែលមានតម្លៃ 300,000$ និងប្រាក់បញ្ញើដែលមានចំនួន 300,000 $ ។ សន្តតិជនដែលជាកូនរបស់មតកជនមានដូចជា A និង B ។ ឪពុកបានគ្រប់គ្រង់ហាងតែម្នាក់ឯង ប៉ុន្តែនៅពេលឪពុកមានអាយុកាន់តែច្រើន កូនប្រុសច្បង A ក៏បានគ្រប់គ្រងអាជីវកម្មនោះតែម្នាក់ឯង។ គេបានវាយតម្លៃថា ការចូលរួមចំណែករបស់ A ក្នុងការរក្សា និង ការបង្កើនទ្រព្យសម្បត្តិរបស់មតកជនស្មើនឹង 200,000 $។

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

C. ភាគនៃវិភាគទាន （CC1166）

“ករណីសិក្សា1”



## 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្ដែង

C. ភាគនៃវិភាគទាន （CC1166）
"ករណីសិក្សា1"

① "តម្លៃទ្រព្យដែលមាននៅពេលចាប់ផ្ដើមសន្តតិកម្ម" ＝ 600,000 $( ដី និង អាគារ 300,000 $ + ប្រាក់បញ្ញើ 300,000 $ )

② ភាគនៃវិភាគទានរបស់ A ＝200,000$

③ ទ្រព្យសម្បត្តិដែលត្រូវចាត់ទុកថាជាមត៌ក ＝400,000 $ （ទ្រព្យសកម្មនៅពេលចាប់ផ្ដើមសន្តតិកម្ម 600,000 $ - ភាគនៃវិភាគទានរបស់ A 200,000 $）

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

C. ភាគនៃវិភាគទាន（CC1166）

"ករណីសិក្សា 1"

④ ការកំណត់ចំណែកមត៌កជាក់ស្តែង

A：400,000$（400,000$/2នាក់ + ភាគនៃវិភាគទាន200,000$）

B：200,000$（400,000$/2នាក់）

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

C. ភាគនៃវិភាគទាន (CC1166)
"ករណីសិក្សា2"

នៅពេលទទួលមរណភាព ឪពុកដែលត្រូវជាមតកជន មានដី និង អាគារដែលមានតម្លៃ 300,000$ និង ប្រាក់បញ្ញើចំនួន 300,000 $។ សន្តតិជនមានដូចជា A និង B ដែលត្រូវជាកូនរបស់មតកជន។ ឪពុកបាន គ្រប់គ្រងអាជីវកម្មតែម្នាក់ឯង ប៉ុន្តែ ដោយសារតែឪពុកមានអាយុកាន់តែច្រើន កូនប្រុសច្បង A ក៏បានធ្វើ ការគ្រប់គ្រង់អាជីវកម្មនោះតែម្នាក់ឯង។ គេបានវាយតម្លៃថា ការចូលរួមចំណែករបស់ A ក្នុងការរក្សា និង ការបង្កើនទ្រព្យសម្បត្តិរបស់មតកជនស្មើនឹង 200,000 $។ ហើយ ដោយសារតែ B បានសុំឲ្យឪពុកជួយ ឧបត្ថម្ភក្នុងការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន ដូច្នេះឪពុកក៏បានផ្តល់ប្រាក់ឲ្យចំនួន 200,000 $។

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្ដែង

C. ភាគនៃវិភាគទាន (CC1166)

"ករណីសិក្សា2"



# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក
## (3) ចំណែកមត៌កជាក់ស្តែង

C. ភាគនៃវិភាគទាន （CC1166）
‶ករណីសិក្សា2″

① ‶តម្លៃទ្រព្យសម្បត្តិដែលមាននៅពេលចាប់ផ្តើមសន្តតិកម្ម″ = 600,000$ ( ដី និង ផ្ទះ 300,000 $ + ប្រាក់បញ្ញើ 300,000 $ )

② ការទទួលផលប្រយោជន៍ពិសេសរបស់ B = 200,000 $ ភាគនៃវិភាគទានរបស់ A = 200,000 $

③ ទ្រព្យសម្បត្តិដែលត្រូវចាត់ទុកថាជាមត៌ក ＝600,000 $ ( ទ្រព្យសកម្មនៅពេលចាប់ផ្តើមសន្តតិកម្ម 600,000$ + ការទទួលផលប្រយោជន៍ពិសេសរបស់ B 200,000 $ - ភាគនៃវិភាគទានរបស់ A 200,000 $ )

# 3 បញ្ហាជុំវិញការកំណត់អំពីចំណែកមត៌ក

## (3) ចំណែកមត៌កជាក់ស្តែង

C.ភាគនៃវិភាគទាន （CC1166）
"ករណីសិក្សា2"

④ ការគណនាចំណែកមត៌កជាក់ស្តែង

A： 500,000$（600,000$/2នាក់ + ភាគនៃវិភាគទាន200,000$）

B： 100,000$（600,000 $/2 នាក់ – ការទទួលផលប្រយោជន៍ពិសេស 200,000 $）

## 4 បញ្ហាជុំវិញការបែងចែកមត៌ក

### (1) លំហូរនៃការបែងចែកមត៌ក

១. ទំហំនៃសន្តតិជន・ចំណែកសន្តតិកម្មតាមច្បាប់

↓

២. ទំហំនៃមត៌ក

↓

៣. ការវាយតម្លៃមត៌ក

↓

៤. កំណត់ចំណែកមត៌កជាក់ស្តែង

↓

៥. ដីកាសម្រេចអំពីវិធីបែងចែក

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (2) ទំហំនៃសន្តតិជន

- ក្នុងករណីដែលមិនដឹងអំពីសន្តតិជន តើយើងត្រូវស្រាវជ្រាវដោយវិធីណា？

⇒ ស្រាវជ្រាវពីទំនាក់ទំនងនៃអត្តសញ្ញាណរបស់មតកជនចាប់ពីពេលចាប់កំណើតរហូតដល់ពេលទទួលមរណភាព និង បង្កើតតារាងទំនាក់ទំនងសន្តតិកម្ម។

- សាកសួរពត៌មានពីកូនក្តី
- ការប្រមូលឯកសារបញ្ជាក់ពីអត្តសញ្ញាណ （សៀវភៅគ្រួសារ សំបុត្រកំណើត សៀវភៅស្នាក់នៅ ជាដើម）
- សាកសួរពត៌មានពីសហព័ទ្ធរបស់មតកជន ញាតិលោហិតខ្សែផ្ទាល់ និងបងប្អូនប្រុសស្រី ជាអាទិ៍
- សាកសួរពត៌មានពី ភូមិ ឃុំ សង្កាត់

※ ក្នុងករណីដែលមានវិវាទអំពីទំហំនៃសន្តតិជន ត្រូវដោះស្រាយតាមនីតិវិធីទាក់ទងនឹងឋានៈបុគ្គលជាអាទិ៍។

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (3) ទំហំនៃមត៌ក

A. ការស្រាវជ្រាវមត៌ក

មត៌កដែលជាកម្មវត្ថុនៃការបែងចែក គឺជាទ្រព្យសកម្មដែលមិនទាន់បានបែងចែកនៅឡើយនៅពេលបែងចែកមត៌ក នៅក្នុងចំណោមសិទ្ធិនិងករណីយកិច្ចដែលស្ថិតនៅក្រោមទ្រព្យសម្បត្តិរបស់មតកជននៅពេលចាប់ផ្តើមសន្តតិកម្ម (CC1147 I) ។

B. បញ្ហានៃការបញ្ចូល ឬ មិនបញ្ចូលជាមត៌ក

រឿងក្តីរដ្ឋប្បវេណី

(A) ក្នុងករណីដែលមានវិវាទពាក់ព័ន្ធនឹងការបញ្ចូល ឬ មិនបញ្ចូលទ្រព្យសម្បត្តិណាមួយជាមត៌កទេ ជាចុងក្រោយបញ្ហានេះនឹងត្រូវដោះស្រាយតាមនីតិវិធីរដ្ឋប្បវេណី ដូច្នេះ ជាទូទៅគេតែងអនុវត្តតាមនីតិវិធីរដ្ឋប្បវេណីជាមុន

→ បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមត៌ក

(B) ចំណុចដែលត្រូវប្រុងប្រយ័ត្នពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ

ទាក់ទងនឹងទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ (CC973) គឺមានតែចំណែកកម្មសិទ្ធិអវិភាគរបស់មតកជនប៉ុណ្ណោះដែលក្លាយជាមត៌ក។

# 4 បញ្ហាជុំវិញការបែងចែកមត៌ក
## (3) ទំហំនៃមត៌ក

C. បញ្ហាចំពោះការក្លាយជាកម្មវត្ថុ ឬ មិនមែនជាកម្មវត្ថុនៃការបែងចែកមត៌ក

(A) សិទ្ធិលើបំណុលជាប្រាក់

ជាទូទៅសិទ្ធិលើបំណុលនេះនឹងបែងចែកទៅតាមចំណែកនៃសន្តតិកម្មតាមច្បាប់ (CC1148 I ) ប៉ុន្តែ បើសិនជាមានការព្រមព្រៀងរវាងសន្តតិជន សិទ្ធិលើបំណុលនោះអាចជាកម្មវត្ថុនៃការបែងចែក។

(B) កាតព្វកិច្ច

មិនមែនជាកម្មវត្ថុនៃការបែងចែកមត៌កនោះទេ (CC1148 I ) ។

D. វត្ថុជំនួស ជាអាទិ៍ (CC1272)

(A) ផលផ្អែកលើសិទ្ធិដែលស្ថិតក្នុងមត៌ក

(B) ប្រាក់សំណងការខូចខាតជាអាទិ៍ដែលបានធ្វើលទ្ធកម្ម ដោយការសងជំនួសការបាត់បង់ ការខូចខាត ឬ ការបំពានកម្មវត្ថុនៃមត៌ក

(C) ប្រាក់លក់ដែលបានធ្វើលទ្ធកម្មជាអាទិ៍ ដោយកិច្ចសន្យាដែលយកមត៌កជាកម្មវត្ថុ

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (3) ទំហំនៃមត៌ក

E. បណ្តឹងទាមទារឲ្យបញ្ជាក់អំពីមត៌ក

“ឧទាហរណ៍នៃការបញ្ជាក់មត៌ក”

មតកជន A — សហព័ទ្ធ B

កូនC

កូនD



C

អចលនវត្ថុ L មានចុះបញ្ជីឈ្មោះរបស់ D ប៉ុន្តែ តាមការពិត វាជាកម្មសិទ្ធិរបស់ A ហើយវាជា មត៌ករបស់ A។



D

ខ្ញុំបានទទួលអចលនវត្ថុ L ពី A តាំងពី 10 ឆ្នាំមុនមក ហើយវាជាកម្មសិទ្ធិរបស់ខ្ញុំ។



អចលនវត្ថុL

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (3) ទំហំនៃមត៌ក

E. បណ្ដឹងទាមទារឲ្យបញ្ជាក់មត៌ក
“បណ្ដឹងទាមទារឲ្យបញ្ជាក់មត៌ក”

រឿងក្ដីរដ្ឋប្បវេណី



C

បណ្ដឹងទាមទារឲ្យបញ្ជាក់មត៌ក





D

អចលនវត្ថុ L មានចុះបញ្ជីឈ្មោះរបស់ D
ប៉ុន្តែ វាជាកម្មសិទ្ធិរបស់ A ។



B

※ ※តម្រូវឲ្យសហសន្តតិជនទាំងអស់ធ្វើជាភាគី（សហបណ្ដឹងចាំបាច់ដោយពិត（CCP41））

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (3) ទំហំនៃមត៌ក

E. បណ្ដឹងទាមទារឲ្យបញ្ជាក់មត៌ក

“ឧទាហរណ៍សេចក្ដីសម្រេចបញ្ចប់នៃបណ្ដឹងទាមទារឲ្យបញ្ជាក់មត៌ក”



C

បណ្ដឹងទាមទារឲ្យបញ្ជាក់មត៌ក



បញ្ជាក់ថា អចលនវត្ថុL (ព័ត៌មានសម្រាប់កំណត់អំពីដីL) គឺជាមត៌ករបស់មតកជន A។

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (4) ការវាយតម្លៃមត៌ក

### A. វិធីវាយតម្លៃ

- វាយតម្លៃ
- ប្រសិនបើមានការព្រមព្រៀងអំពី តម្លៃនៃការវាយតម្លៃ វិធីវាយតម្លៃ គេអាចសម្រេចតាមការព្រមព្រៀងនោះបាន។

### B. អចលនវត្ថុ

- នៅប្រទេសជប៉ុន តុលាការអាចបង្គាប់ឲ្យដាក់ឯកសារដូចជា លិខិតវាយតម្លៃអចលនវត្ថុ លិខិតប្រកាសពន្ធសន្តតិកម្ម និង លិខិតវាយតម្លៃរបស់ក្រុមហ៊ុនអចលនវត្ថុធំៗ ដើម្បីសម្របសម្រួលយោបល់របស់ភាគី និង ឈានទៅដល់ការព្រមព្រៀង។
- ក្នុងករណីដែលមិនអាចព្រមព្រៀងគ្នាទេ តុលាការនឹងជ្រើសរើសអ្នកវាយតម្លៃដែលជាបុគ្គលមានចំនេះដឹងដូចជាអ្នកជំនាញវាយតម្លៃអចលនវត្ថុជាដើម មកឲ្យវាយតម្លៃ។

# 4 បញ្ហាជុំវិញការបែងចែកមត៌ក
## (5) ដីកាសម្រេចអំពីវិធីបែងចែក

A. ប្រភេទនៃវិធីបែកចែក

(A) ការបែងចែកវត្ថុ (វត្ថុផ្ទាល់)

វិធីបែងចែកដោយបែងចែកវត្ថុផ្ទាល់

(B) ការបែងចែកតាមការសងជំនួស （CC1267Ⅱ）

វិធីបែងចែកដោយឲ្យសន្តតិជនណាមួយធ្វើលទ្ធកម្មលើទ្រព្យម្បត្តិលើសពីចំណែកនៃសន្តតិកម្មតាមច្បាប់ ហើយជំនួសមកវិញដោយការបង់ប្រាក់សម្រួលទៅតាមសមាមាត្រនៃចំណែកឲ្យសន្តតិជនផ្សេងទៀត។

(C) ការបែងចែកដោយប្តូរជាប្រាក់ （CC1271）

វិធីបែងចែកដោយលក់មត៌ក ហើយបែងចែកប្រាក់ថ្លៃលក់នោះ (លក់ដោយស្មគ្រ័ចិត្ត លក់ដោយបង្ខំ)

(D) ការបែងចែកដោយអវិភាគ

វិធីដែលឲ្យសន្តតិជនធ្វើលទ្ធកម្មដោយអវិភាគតាមបញ្ញត្តិសិទ្ធិប្រត្យក្ស （CC202） ទៅតាមចំណែកសន្តតិកម្មជាក់ស្តែងនៃមត៌ក

→ បណ្តឹងទាមទារឲ្យបែងចែកវត្ថុអវិភាគ （CC212）

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (5) ដីកាសម្រេចអំពីវិធីបែងចែក

B. កត្តាត្រូវពិចារណា （CC1270Ⅱ）

(A) ប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក ឬ អាយុ មុខរបរ ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត ស្ថានភាពជីវភាពរបស់សហសន្តតិជននីមួយៗ និង ស្ថានភាពផ្សេងទៀត （CC1267Ⅰ）

a. ប្រភេទ និង លក្ខណៈនៃវត្ថុ ឬ សិទ្ធិដែលមាននៅក្នុងមត៌ក

ខាងលើនេះគឺជាខ្លឹមសារនៃមត៌ក។ វិធីបែងចែកគឺមានភាពខុសគ្នាទៅតាមករណីនីមួយៗដូចជា ករណីមានតែ អចលនវត្ថុ ឬ ករណីទ្រព្យសម្បត្តិចរន្តក្រៅពីអចនលវត្ថុ ជាអាទិ៍។

b. មុខរបរ

ចំពោះសន្តតិជនដែលទទួលមុខរបរបន្តពីគ្រួសារ តុលាការភាគច្រើនបង្គាប់ឲ្យសន្តតិជននោះធ្វើលទ្ធកម្មនូវអចលនវត្ថុ ឬ ភាគហ៊ុនដែលចាំបាច់សម្រាប់ដំណើរការមុខរបរ។

c. អាយុ និង ស្ថានភាពផ្លូវកាយ និង ផ្លូវចិត្ត

ចំពោះជនជរា យុវជន ជនមានកាយសម្បទាមិនគ្រប់គ្រាន់ តុលាការត្រូវពិចារណាចំពោះបុគ្គលទាំងនោះ។

d. ស្ថានភាពជីវភាព និងស្ថានភាពផ្សេងទៀត

ស្ថានភាពនៃការប្រើប្រាស់មត៌កតាំងពីដើមមកជាអាទិ៍ក៏ត្រូវយកមកពិចារណា។

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (5) ដីកាសម្រេចអំពីវិធីបែងចែក

B. កត្តាត្រូវពិចារណា （CC1270Ⅱ）

(B) សិទ្ធិអាទិភាពរបស់សហព័ទ្ធ （CC1268）

នៅក្នុងការបែងចែកទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ សហព័ទ្ធមានអាទិភាពជាងសហសន្តតិជនផ្សេងទៀត ក្នុងការទទួលយកចំណែកកម្មសិទ្ធិអវិភាគរបស់មតកជន រហូតដល់គ្រប់ចំនួននៃចំណែកសន្តតិកម្ម។

(C) សំណងនៃកាតព្វកិច្ចរបស់មតកជន （CC1269）

កាតព្វកិច្ចមិនមែនជាកម្មវត្ថុនៃដីកាសម្រេចអំពីការបែងចែកមត៌កនោះទេ ហើយសន្តតិជនត្រូវទទួលបន្តតាមចំណែកនៃសន្តតិកម្មតាមច្បាប់ ហេតុនេះសន្តតិជនត្រូវបែងចែកមត៌កដោយពិចារណាពីការណ៍ដែលខ្លួនត្រូវសងកាតព្វកិច្ចនោះ។

(D) ទំនៀមទម្លាប់នៅក្នុងតំបន់ និង មតិលើសពីពាក់កណ្តាលរបស់សហសន្តតិជន CC1270Ⅱ)

ប្រសិនបើមិនផ្ទុយនឹងទំនៀមទំម្លាប់ក្នុងតំបន់ទេ តុលាការគួរតែគោរពតាមឆន្ទៈរបស់សន្តតិជនតាមតែអាចធ្វើទៅបាន។

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (5) ដីកាសម្រេចអំពីវិធីបែងចែក

C. ការស្រាវជ្រាវពីវិធីបែងចែកជាក់ស្ដែង

(A) ការសម្របសម្រួលចំពោះការបែងចែកវត្ថុ

យោងតាមបំណងរបស់សន្តតិជនគ្រប់រូប និង ពិចារណាលើកត្តាដែលត្រូវពិចារណាខាងលើ តុលាការអាចបង្គាប់ឲ្យសន្តតិជននីមួយៗធ្វើលទ្ធកម្មតាមទំហំជាក់ស្ដែងនៃចំណែកសន្តតិកម្មរៀងៗខ្លួនលើវត្ថុដែលជាមត៌កបាន។

(B) ការប្រើប្រាស់រួមគ្នាតាមវិធីនៃការបែងចែកវត្ថុ និងការបែងចែកតាមការសងជំនួស

មានករណីជាច្រើនដែលតុលាការប្រើប្រាស់រួមគ្នាបន្ថែមពីលើចំណុច (A) ដោយបង្គាប់ឲ្យសន្តតិជនដែលទទួលបានមត៌កលើសពីចំណែកមត៌កជាក់ស្ដែង បង់ប្រាក់សម្រួលដែលស្មើនឹងចំនួនដែលលើសនោះ។

(C) ការបែងចែកដោយប្ដូរជាប្រាក់

ចំពោះវត្ថុដែលគ្មានសន្តតិជនណាចង់ធ្វើលទ្ធកម្ម តុលាការនឹងបែងចែកដោយប្ដូរជាប្រាក់។ នៅក្នុងចំណុច (B) ប្រសិនបើសន្តតិជននោះគ្មានធនធានគ្រប់គ្រាន់សម្រាប់បង់ប្រាក់សម្រួលឲ្យសន្តតិជនផ្សេងទៀតទេ ក៏តុលាការអាចធ្វើការបែងចែកដោយប្ដូរជាប្រាក់បានដែរ ប្រសិនបើមិនអាចជៀសវាងបាន ។

(D) ការបែងចែកដោយអវិភាគ

ក្នុងករណីដែលជម្រើសនៃការបែងចែកចំណុច(A)~(C) មិនអាចធ្វើបាន តុលាការអាចសម្រេចខុសពីធម្មតាដោយបែងចែកអវិភាគ។

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (5) ដីកាសម្រេចអំពីវិធីបែងចែក

"ចំណុចប្រុងប្រយ័ត្ន"

• តើសន្តតិជនបរទេសអាចទទួលសន្តតិកម្មលើមត៌កដែលមានរួមទាំងអចលនវត្ថុដែរឬទេ ?

⇒ បើពុំមានសញ្ជាតិជាខ្មែរទេ មិនអាចធ្វើលទ្ធកម្មតាមសន្តតិកម្ម ឬ អច្ច័យទានលើដីធ្លីបានទេ (CC1155 I)

⇒ ធ្វើការសម្រួលជា សាច់ប្រាក់ ចលនវត្ថុ ឬ ប្រាក់បញ្ញើឲ្យទៅសន្តតិជនបរទេសដែលមិនអាចធ្វើលទ្ធកម្មនូវអចលវត្ថុ (CC1155 II)

⇒ ក្នុងករណីដែលសន្តតិជនទាំងអស់ជាជនបរទេស សន្តតិជនទាំងអស់ត្រូវសហការគ្នាលក់អចលនវត្ថុដើម្បីប្តូរជាប្រាក់ក្នុងអំឡុងពេល ៣ខែ រួចធ្វើការបែងចែក។ (CC1155III～V)

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (6) ករណីសិក្សា

X ស្លាប់, ប្រពន្ធ A, គ្មានកូន, ម្តាយ B, បងប្រុស C

ដីលំនៅឋាន (ទ្រព្យសម្បត្តិរួមរបស់ប្តីប្រពន្ធ) ប្រាក់ក្នុងគណនី និង រថយន្ត









# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (6) ករណីសិក្សា

A. ទំហំនៃសន្តតិជន និង ចំណែកមត៌កដែលច្បាប់បានកំណត់

(A) X បានទទួលមរណភាពនៅថ្ងៃទី... ខែ...ឆ្នាំ.... ហើយសន្តតិកម្មបានចាប់ផ្តើម។
សន្តតិជនរួមមាន ប្រពន្ធA និង ម្តាយ B របស់មតកជន។

(A) ចំណែកមត៌កដែលច្បាប់បានកំណត់ A បាន 1 ភាគ 2 និង B បាន 1 ភាគ 2។

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (6) ករណីសិក្សា

### B. ទំហំ និង ការវាយតម្លៃមត៌ក

មត៌ករបស់មតកជនមាននៅក្នុងបញ្ជីសារពើភ័ណ្ឌ 1 ដល់ 3 ។

បញ្ជីសារពើភ័ណ្ឌ

1 អចលនវត្ថុ

ទីតាំងស្ថិតនៅ ភូមិ....... ឃុំ..........ស្រុក........ខេត្ត.......... ទំហំ ............m²

លេខប័ណ្ណ .............

លេខក្បាលដី ...............

(ការវាយតម្លៃ 300,000$) (ប៉ុន្តែ មត៌កមានតែចំណែកអវិភាគ 1 ភាគ 2)

2 ប្រាក់ក្នុងកុង ធនាគារឈ្មោះ........ សាខា............កុងសន្សំធម្មតា (គណនីលេខ.......)

85,000$

3 រថយន្ត ស្លាកលេខរថយន្ត.......លេខតួ........... (ការវាយតម្លៃ 5000$)

## 4 បញ្ហាជុំវិញការបែងចែកមត៌ក

### (6) ករណីសិក្សា

C. កំណត់ចំណែកមត៌កជាក់ស្តែង

（300,000×1/2＋85,000＋5,000）×1/2＝120,000$

A: 120,000$

B: 120,000$

## 4 បញ្ហាជុំវិញការបែងចែកមត៌ក

### (6) ករណីសិក្សា

### D. ដីកាសម្រេចអំពីវិធីបែងចែក

#### (A) សាវតា និង ឆន្ទៈរបស់ភាគី ជាអាទិ៍

a. អំពី A

- A ជាបុគ្គលិកធ្វើការក្នុងក្រុមហ៊ុន មានប្រាក់ខែសម្រាប់ទ្រទ្រង់ជីវភាព ព្រមទាំងមានប្រាក់សន្សំលើសពី 100,000$។
- A បានរស់នៅក្នុងផ្ទះដែលជាមត៌កក្នុងរឿងក្ដីនេះជាមួយ X រយៈពេល 10ឆ្នាំហើយ។
- A បានប្រើប្រាស់រថយន្តដែលជាមត៌កក្នុងរឿងក្ដីនេះជាប្រចាំថ្ងៃ។
- A មានបំណងធ្វើលទ្ធកម្មតែម្នាក់ឯងលើចំណែកអវិភាគនៃដី និង រថយន្តដែលជាមត៌កក្នុងរឿងក្ដីនេះ។

b. អំពី B

- B មានវ័យចំណាស់ ហើយកំពុងរស់នៅជាមួយ C។ គាត់មានជីវភាពមិនសូវធូធារទេ និងរស់នៅពឹងផ្អែកលើប្រាក់សោធននិវត្តន៍។
- B មានបំណងធ្វើលទ្ធកម្មលើប្រាក់ក្នុងកុង។ ហើយចង់ឲ្យលក់អចលនវត្ថុ និង រថយន្តដែលជាមត៌កក្នុងរឿងក្ដីនេះ ហើយបែងចែកប្រាក់។

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (6) ករណីសិក្សា

### D. ដីកាសម្រេចអំពីវិធីបែងចែក

#### (B) ការពិចារណាអំពីវិធីបែងចែក

- អចលនវត្ថុនៃរឿងក្ដីនេះជាទ្រព្យសម្បត្តិរួមរបស់ប្ដីប្រពន្ធ ហើយ A មានចំណែកអវិភាគ 1 ភាគ 2។ A អាចធ្វើលទ្ធកម្មដោយអាទិភាពលើចំណែកអវិភាគនៃអចលនវត្ថុនៃរឿងក្ដីនេះ រហូតដល់គ្រប់ចំណែកសន្តតិកម្មបាន （CC1268）។
- A បានរស់នៅលើអចលនវត្ថុ និង ប្រើប្រាស់រថយន្តនៃរឿងក្ដីនេះ ចាប់តាំងពី X នៅរស់មក។
- A មានធនធានគ្រប់គ្រាន់ដើម្បីបង់ប្រាក់សម្រួល។ ប៉ុន្តែ B មើលទៅដូចជាគ្មានធនធានគ្រប់គ្រាន់នោះទេសម្រាប់បង់ប្រាក់សម្រួល។

→ ហេតុនេះ គួរតែឲ្យ B ធ្វើលទ្ធកម្មលើប្រាក់បញ្ញើក្នុងគណនីធនាគារ ហើយ A ធ្វើលទ្ធកម្មលើអចលនវត្ថុ និង រថយន្តនៃរឿងក្ដីនេះ និងបង់ប្រាក់សម្រួលដែលទទួលបានលើសវិញ។

A : ចំនួនលទ្ធកម្ម អចលនវត្ថុ (ចំណែកអវិភាគ 1 ភាគ 2) រថយន្ត→155,000$

B : ចំនួនលទ្ធកម្ម ប្រាក់បញ្ញើក្នុងគណនីធនាគារ 85,000$

ប្រាក់សម្រួល 155,000－120,000＝35,000$

# 4 បញ្ហាជុំវិញការបែងចែកមត៌ក

## (6) ករណីសិក្សា

E. "សេចក្ដីសម្រេចបញ្ចប់" (ការប្រើប្រាស់រួមគ្នាតាមវិធីនៃការបែងចែកវត្ថុ និងការបែងចែកតាមការសងជំនួស)

សម្រេចបែងចែកមត៌ករបស់មតកជនដូចខាងក្រោម៖

①. អ្នកដាក់ពាក្យសុំ A ធ្វើលទ្ធកម្មនូវចំណែកអវិភាគ 1 ភាគ 2 នៃអចលនវត្ថុដូចក្នុងបញ្ជីសារពើភ័ណ្ឌ 1 និង រថយន្តដូចក្នុងបញ្ជីសារពើភ័ណ្ឌ 3 ។

②. ភាគីម្ខាងទៀត B ធ្វើលទ្ធកម្មប្រាក់បញ្ញើក្នុងគណនីដូចក្នុងបញ្ជីសារពើភ័ណ្ឌ 2 ។

③. បង្គាប់ឲ្យអ្នកដាក់ពាក្យសុំ A បង់ប្រាក់ចំនួន 35,000$ ដែលជាប្រាក់សម្រួលនៃលទ្ធកម្មមត៌កខាងលើឲ្យទៅភាគីម្ខាងទៀត។

# Fin.

"ឯកសារយោង"

**The Legal and Judicial Development Project (Phase V)**

https://www.jica.go.jp/project/english/cambodia/025/materials/index.html